ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ២០៣៧ កសក

រាជធានីភ្នំពេញ, ថ្ងៃទី.០៣...ខែ.០៦.ឆ្នាំ ២០១៥

សូមគោរពជូន

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

-ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃព្រឹទ្ធសភា

-ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃរដ្ឋសភា

-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ

-ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅរមក្រសួងព្រះបរមរាជវាំង

-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា

-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា

-ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

-ឯកឧត្តមនាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំត្រីមាសទី១ ឆ្នាំ២០១៥** និងទិសដៅអនុវត្តបន្ត ។

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមផ្ញើជូនឯកឧត្តម នូវរបាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំត្រីមាសទី១ ឆ្នាំ២០១៥** ចំនួន០១ច្បាប់ ដើម្បីជូនជ្រាបជាសេចក្តីរាយការណ៍ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

រដ្ឋមន្ត្រី

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

បណ្ឌិត អ៊ុក រ៉ាប៊ុន

**ចម្លងជូន**

-គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង

-ឯកសារ កាលប្បវត្តិ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ ៖ (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ ៖ (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
## ស្តីពី
## សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
## ប្រចាំត្រីមាសទី១ ឆ្នាំ២០១៥

## I- សភាពការណ៍រួម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអង្គភាពជំនាញជាសេនាធិការបានខិតខំបំពេញភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវដោយតម្រង់ទិសដៅតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលយ៉ាងយកចិត្តទុកដាក់។ ជាក់ស្តែង ក្នុងត្រីមាសទី១ ឆ្នាំ២០១៥នេះ ការងារដាំដុះដំណាំស្រូវប្រាំងសម្រេចបានលើសផែនការ ហើយបានបញ្ចប់ជាស្ថាពរ។ រីឯទិន្នផលគឺកើនលើសឆ្នាំមុនចំនួន៨៥គ.ក្រក្នុងមួយហិកតា។ បច្ចុប្បន្ននេះ ប្រជាកសិករបាននិងកំពុងធ្វើការច្រូតកាត់យ៉ាងមមាញឹកឲ្យទាន់ពេលវេលាដើម្បីជៀសវាងការបាត់បង់ផលស្រូវក្នុងពេលនិងក្រោយច្រូតកាត់។ មកទល់ពេលនេះ លទ្ធផលការងារប្រមូលផលទទួលបានប្រមាណ៩០%។ ក្រៅពីដំណាំស្រូវ ប្រជាកសិករកំពុងមមាញឹកផងដែរលើការដាំដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មផ្សេងៗទៀត។ ដោយឡែក ការនាំចេញផលិតផលកសិកម្មជាពិសេសស្រូវ-អង្ករក៏មានសន្ទុះគួរកត់សម្គាល់ផងដែរបើប្រៀបធៀបនឹងឆ្នាំមុន។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៅតែបន្តចាត់វិធានការជំរុញការអប់រំណែនាំដល់ប្រជាកសិករឲ្យធ្វើកសិកម្មចម្រុះបន្ថែមទៀតនៅតំបន់ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ដោយមិនត្រូវទុកដីឲ្យនៅទំនេរនោះឡើយ។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងត្រីមាសទី១ ឆ្នាំ២០១៥នេះមានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ លទ្ធផលបញ្ចប់ការប្រមូលផលដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៤-២០១៥

ការងារប្រមូលផលស្រូវប្រាំងសម្រេចបានចំនួន៤៤១.៩៣៨ហិកតា ស្មើនឹង៩០,០២ភាគរយ នៃផ្ទៃដីអនុវត្តបានចំនួន៤៩០.៩៣៥ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន១.៩៦៩.៤៧២តោន និងទិន្នផលជាមធ្យមចំនួន៤,៤៥៦តោនក្នុងមួយហិកតា (ឆ្នាំមុនទទួលបានទិន្នផលគិតជាមធ្យមបាន៤,៣៧២តោនក្នុងមួយហិកតា) ក្នុងនោះ៖

- ផ្ទៃដីភ្ជួររាស់សរុបចំនួន៥៨២.៣៨០ហិកតា លើសឆ្នាំមុនចំនួន៣៣.៧៨៨ហិកតា
- ផ្ទៃដីសាបសរុបចំនួន៤.០៣៤ហិកតា តិចជាងឆ្នាំមុនចំនួន៨៣៨ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន៤៩០.៩៣៥ហិកតា ស្មើនឹង១១៧,៧៤ភាគរយនៃផែនការ៤១៦.៩៦៥ហិកតា លើសឆ្នាំមុនចំនួន១.៩៨៣ហិកតា។

#### ១.២ ដំណាំរួមផ្សំ :

- ផ្ទៃដីសម្រេចបានចំនួន៧៤.៩០៣ហិកតា ស្មើនឹង១៧៣,៥១% នៃផែនការចំនួន៤៣.១៦៩ហិកតា តិចជាងឆ្នាំមុនចំនួន៨.២៤៨ហិកតា

- ដំណាំឧស្សាហកម្ម : ផ្ទៃដីសម្រេចបាន១៤.០៧២ហិកតា ស្មើនឹង៦៩,៤៩% នៃផែនការ២០.២៥១ហិកតា តិចជាងឆ្នាំមុនចំនួន៣.៥៣៣ហិកតា។



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Nº 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

គួរកត់សម្គាល់ថា ក្នុងត្រីមាសទី១ ឆ្នាំ២០១៥នេះ អង្គរកម្ពុជា បាននាំចេញទៅកាន់ទីផ្សារក្រៅប្រទេសមានបរិមាណសរុបចំនួនជាង១៤៩៣ាន់តោន ដែលឆ្នាំមុននាំចេញបានតែជាង៨៤ពាន់តោន ប៉ុណ្ណោះក្នុងរយៈពេលដូចគ្នា គឺកើនឡើង៧៧% ។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិ-ឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៤៤,៣១ | ១៣០,៩០ | ១១១,៤៦ |
| សរុប I | | ៤០៦,៦០ | ៣៤៤,៣១ | ១៣០,៩០ | ១១១,៤៦ |
| II-ចម្ការកៅស៊ូកសិ-ឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១០.៧១៩,២៧ | ៥.៣២៧,០៥ | ៥.៨០៦,១៨ | ២.០១៤,៣២ |
| ២ | ក្រុមហ៊ុន ស៊ីហ្វរ៉ាប់ប៊ើលីមីធីត (រតនគីរី) | ៧៨,៥៣ | ២.០៦៤,៣០ | ២១៥,៥៨ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ១.០៨២,១២ | ២៧២,៥៣ | ២០០,០០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.៥៧១,៥២ | ៣.១៣៩,៨៣ | ១.៦៥៧,៧៩ | ១.២៣៤,០០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.៣៤៦,៦៩ | ១.៣១៤,៩៩ | ៥៤៦,៩៦ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វរីសស៍ (ស្នួល) | ១.៧៤៤,៧៨ | ២.៦៤១,៤៣ | ៦៣២,៥៤ | ៤០០,០០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.០២៩,៧០ | ១.២៣៧,៥៩ | ៦០៩,៣០ | ១៣១,៦០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣.១១១,៦៥ | ១.២១៥,៥៥ | ៥៩៩,៦៩ | ២២៨,៤០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ១.២៧២,៦០ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.៣៤៧,៩២ | ១.៧២៧,៩៣ | ៩៦០,០០ |
| សរុប II | | ២៨.១៥៩,៥៤ | ២៥.៦៧៥,០៨ | ១២.៨៣៦,៥៣ | ៥.៧១៥,២៨ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៧០៨,០០ | ១៤១.២០៤,០០ | ៧៥៧,៣៣ | ១៣,២០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៦១.២៧១,០០ | ៧៦.១៤៧,០០ | ១២.៥៣៦,០០ | ៥.៦២៥,០០ |
| សរុប III | | ៦១.៩៧៩,០០ | ២១៧.៣៥១,០០ | ១៣.២៩៣,៣៣ | ៥.៨៥៣,១៤ |
| សរុប I+II+III | | ៩០.៥៤៥,១៤ | ២៤៣.៣៧០,៣៩ | ២៦.២៦០,៧៦ | ១១.៤៦៤,៩៤ |

ចំពោះតម្លៃកៅស៊ូក្នុងខែកន្លងមកនេះគឺបានធ្លាក់មកនៅត្រឹម១.៣៣១ដុល្លារអាមេរិក/តោន។ ប៉ុន្តែទោះជាយ៉ាងណាក្រោមកិច្ចសហការជាមួយបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ១១ប្រទេស ក្នុងនោះក៏មានកម្ពុជាផងដែរ ដែលសង្ឃឹមថា តម្លៃកៅស៊ូនឹងកើនឡើងវិញតាមរយៈការរិះរកវិធានការសមស្របនានាប្រកបដោយស្ថិរភាពសម្រាប់ជាប្រយោជន៍ដល់អ្នកដាំកៅស៊ូ ។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ចូលរួមការងារជាមួយជំនាញការអង្គការ UNIDO ដើម្បីសិក្សាលើការប្រើប្រាស់ឧបករណ៍ និងម៉ាស៊ីនធ្វើតេស្តកៅស៊ូរលកានីសេ និងនីតិវិធីធ្វើតេស្តសម្រាប់វាយតម្លៃគុណភាពនៃផលិតផលកៅស៊ូ
- បើកវគ្គបណ្តុះបណ្តាលស្តីពីការដាំដុះនិងថែទាំកៅស៊ូនៅស្ថានីយអនុវត្ត ដែលមានអ្នកចូលរួមចំនួន៣២នាក់
- វិភាគសរីរៈទឹកជ័រលើចម្ការពិសោធន៍ក្លូន PB260, PB330 និង IRCA209
- លាបថ្នាំរំញោចអេតេហ្វូនគ្រប់ចម្ការពិសោធន៍ទាំងក្នុងនិងក្រៅស្ថានីយ
- បង្កើតចម្ការពិសោធន៍ជីចំនួន៤ ក្នុងឆ្នាំ២០១៥ លើក្លូនGT1 និង RRIM712 លើប្រភេទដីគីមីចំនួន២ប្រភេទ NPK 15.15.15 និង NPK15.7.18
- ផ្គត់ផ្គង់មែកពូជកៅស៊ូជូនក្រុមហ៊ុនចម្ការកៅស៊ូទ្រីភាពបឹងទន្លេប្រេច បានចំនួន១៥ក្លូន ស្មើ៩៤៥ម៉ែត្រ

- ទទួលនិស្សិតសាលាជាតិកសិកម្មកំពង់ចាមចំនួន៣៧នាក់ ចុះទស្សនកិច្ចសិក្សា។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

### ៣.១ ការងារចិញ្ចឹមសត្វ

- ចុះណែនាំកសិករឱ្យចេះធ្វើការជ្រើសរើសពូជល្អមកចិញ្ចឹម
- ជំរុញនិងអប់រំប្រជាកសិករចិញ្ចឹមគោទឹកដោះនៅរាជធានីភ្នំពេញ
- ជំរុញប្រជាកសិករឲ្យមានការយល់ដឹងច្រើនលើការកែលម្អពូជគោ ក្របី ជ្រូក និងបក្សី ពិសេស ការកែលម្អពូជគោនិងជ្រូកដោយការបង្កាត់សិប្បនិម្មិត។
- ការងារឡជីវៈឧស្ម័នៈ កម្មវិធីឡជីវៈឧស្ម័នថ្នាក់ជាតិ (NBP) អនុវត្តនៅខេត្តកំពង់ចាម កណ្តាល ស្វាយរៀង តាកែវ កំពង់ស្ពឺ កំពង់ឆ្នាំង កំពត ព្រៃវែង សៀមរាប ពោធិ៍សាត់ កំពង់ធំ ត្បូងឃ្មុំ សាងសង់បាន១៩៩ឡ (របាយការណ៍ខែកុម្ភៈ ឆ្នាំ២០១៥) ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន និងផលិតឡជីវឧស្ម័នសរុបចំនួន៣១៩ឡ។
- ការងារដំណាំចំណីសត្វ ៖
- តាមបណ្តាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ធ្វើការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ
- គម្រោង CAIT (Center International for Tropical Agriculture) បានអនុវត្តនៅក្នុងខេត្តកំពង់ចាម ពោធិ៍សាត់ និងរតនគិរី។

### ៣.២ ការងារវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ

- ជ្រូកសរុបចំនួន៣០១ក្បាល នៅក្នុងស្ថានីយពិសោធន៍ពូជជ្រូក ក្នុងនោះជ្រូកបាចំនួន០៩ក្បាល ជ្រូកមេចំនួន៩៣ក្បាល និងកូនជ្រូកចំនួន១៧១ក្បាល
- គោសរុបចំនួន១៥៨ក្បាល នៅក្នុងស្ថានីយចិញ្ចឹមគោ ក្នុងនោះគោបាចំនួន០៤ក្បាល គោមេប្រាម៉ាន់កាត់ចំនួន៣៥ក្បាល គោជំទង់ចំនួន៣៦ក្បាល គោបៅដោះចំនួន៤២ក្បាល និងគោកំផែងសែនចំនួន៤១ក្បាល
- វិទ្យាស្ថានបានខិតខំពង្រឹងសកម្មភាពពិសោធន៍ស្រាវជ្រាវដូចខាងក្រោម៖
  + កែច្នៃទឹកមេជីវិតនៅវិទ្យាស្ថានពិសោធន៍ពូជគោនៅភ្នំតាម៉ៅ
  + រៀបចំសកម្មភាពគម្រោងគាំទ្រដោយសហភាពអឺរ៉ុបទាក់ទងនឹងការងារកែច្នៃទឹកមេជីវិតគោ
  + លើកសំណើទៅភាគីចិនដើម្បីបង្កើតមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិតគោ មន្ទីរពិសោធន៍វិភាគចំណីសត្វ មន្ទីរពិសោធន៍សេនេទិច និងមន្ទីរពិសោធន៍កាកសំណល់ថ្នាំសត្វ
  + រៀបចំស្នើសុំទិញឧបករណ៍វិភាគចំណីតាមរយៈគម្រោងសហភាពអឺរ៉ុបនិងគម្រោង SPS។

### ៣.៣ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

- ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី ជំងឺសារទឹកចំនួន៣៨៤.៩៩៩ក្បាល ជំងឺអុតក្តាមចំនួន៦.៣៧៣ក្បាល និងជំងឺបូសខ្យល់ចំនួន១.៤៤២ក្បាល
- ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន៣១.៥០២ក្បាល ជំងឺប៉េស្តចំនួន៥៦.៣៤៧ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន៣៣.៧៥៦ក្បាល ជំងឺអុតក្តាមចំនួន៣.៥៤០ក្បាល ជំងឺអូហ្សេស្គីចំនួន៦.៣០០ក្បាល ជំងឺរាគកូនជ្រូកចំនួន៧.៦៩៦ក្បាល ជំងឺកញ្ជ្រឹលចំនួន២.២០៥ក្បាល ជំងឺជាតិដែកចំនួន៤.៥២៦ក្បាល និងជំងឺផ្លូវដង្ហើមចំនួន២.៨០២ក្បាល
- ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន១០២.១៨៥ក្បាល ជំងឺញីវកាសចំនួន២៨៣.៩៨៣ក្បាល ជំងឺអាសន្នរោគចំនួន១១១.៩៧៧ក្បាល ជំងឺហ្គុមបូរ៉ូចំនួន១.៥៥០ក្បាល និងជំងឺប៉េស្តទាចំនួន១២២.៣៨៥ក្បាល។

### ៣.៤ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

- ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក
- រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ
- អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅតាមខេត្ត-រាជធានី

- បានពិនិត្យវត្ថុវិភាគសរុបចំនួន៩៧៣សំណាក និងផ្នែកសរីរោគសាស្ត្រសរុបចំនួន១៨ក្បាល។

**៣.៥ ការអនុវត្តវិធានបសុពេទ្យ**

- តាមដាន ឃ្លាំមើលជាប្រចាំនូវជំងឺផ្តាសាយបក្សីប្រភេទH5N1 និងH7N9 នៅតាមទីផ្សាររាជធានី ខេត្តទូទាំងប្រទេស និងទទួលទូរស័ព្ទហៅចូលសរុបចំនួន៣ករណី មកពីខេត្តសៀមរាប កំពង់ចាម និងខេត្តកំពង់ស្ពឺ សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព រាយការណ៍ពីបក្សីឈឺ ងាប់ និងវិធានការការពារជំងឺផ្តាសាយបក្សី

- ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោចំនួន៤៨លើក ក្របីចំនួន៤៨លើក ជ្រូកចំនួន១០៦លើក មាន់ចំនួន១២៤លើក ទាចំនួន១៦២លើក កន្លែងពិឃាតមាន់ចំនួន៦៥លើក កន្លែងលក់មាន់ចំនួន១១០លើក ទ្រុងចិញ្ចឹមចំនួន៥៥០លើក បរិវេណភូមិចំនួន១៧លើក សត្តឃាតដ្ឋានចំនួន១១១លើក ផ្លូវជាតិចំនួន២៨លើក និងកន្លែងផ្ទុះជំងឺចំនួន៣លើក។

**៣.៦ ការងារផ្សព្វផ្សាយបច្ចេកទេស**

- ចុះផ្សព្វផ្សាយពីជំងឺឆ្លងសត្វគោក្របីសំខាន់ៗ និងជំងឺផ្តាសាយបក្សីនៅតាមបណ្តារាជធានី/ខេត្ត
- រៀបចំគម្រោងថវិកាតាមកម្មវិធីឆ្នាំ២០១៥ សម្រាប់ការិយាល័យផ្សព្វផ្សាយបច្ចេកទេស
- រៀបចំផែនការសកម្មភាពសម្រាប់ផ្សព្វផ្សាយជាមួយកម្មវិធី EU-PGA-L
- ចងក្រងឯកសារសម្រាប់បញ្ចូលក្នុងទស្សនាវដ្តី និងបោះពុម្ពផ្សព្វផ្សាយ។

## ៤ ផ្នែកព្រៃឈើ

**៤.១ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ**

- ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង កំពង់ធំ និងសៀមរាប) ដែលមានសត្វស្លាបប្រមាណ១៩៥ប្រភេទ (ប្រហែល១១២.៨០៩ក្បាល)

- រៀបចំអាហារដ្ឋានត្មាតនៅព្រៃការពារព្រះវិហារ ស្ទឹងត្រែង និងក្រចេះ ដោយរាប់ឃើញសត្វត្មាតសរុបចំនួនប្រមាណ៦៧ក្បាល

- ការពារសម្បុកសត្វត្រដក់តូចចំនួនប្រមាណ៣២សម្បុក សត្វត្រយ៉ងចង្កំ ក ស ចំនួន២០សម្បុក ត្មាតចំនួន៨ និងរំពេទន្លេចំនួន១១សម្បុក នៅខេត្តស្ទឹងត្រែង ក្រចេះ និងព្រះវិហារ។

**៤.២ ការងារសហគមន៍ព្រៃឈើ**

- ធ្វើការអប់រំផ្សព្វផ្សាយពីសារសំខាន់នៃការអភិរក្សសត្វព្រៃ ពង្រឹងការអនុវត្តច្បាប់ ពង្រឹងសមត្ថភាពគ្រប់គ្រងរបស់គណៈកម្មាធិការសហគមន៍ ក្រុមសន្សំប្រាក់ ការចិញ្ចឹមមាន់ ការអភិវឌ្ឍកសិកម្មជាលក្ខណៈគ្រួសារ ស្រូវសង្គ្រោះសត្វព្រៃ ការអភិរក្សសត្វក្អាន់តាមដងទន្លេមេគង្គ និងការគ្រប់គ្រងកម្មវិធីទេសចរណ៍ធម្មជាតិ ដោយមានអ្នកចូលរួមសរុបចំនួន២.៥៦៨នាក់ (ស្ត្រីចំនួន៣៧៨នាក់)

- ចុះយកទិន្នន័យដីលំនៅដ្ឋានរបស់ប្រជាពលរដ្ឋនៅភូមិដងផ្លិតនិងភូមិប្រា បានចំនួន៣២៨ក្បាលដី ត្រូវជា៣២០គ្រួសារ ដើម្បីធ្វើផែនទីប្រើប្រាស់ដីជាក់ស្តែង និងបិទផែនទីប្រកាសជាសាធារណៈអំពីលទ្ធផលនៃការប្រមូលទិន្នន័យស្តីពីការប្រើប្រាស់ដីរបស់ប្រជាពលរដ្ឋភូមិដងផ្លិត រួមមានដីកសិកម្មនិងដីលំនៅដ្ឋាន ដើម្បីឲ្យប្រជាពលរដ្ឋធ្វើការត្រួតពិនិត្យនិងកែសម្រួលក្បាលដីដែលមានបញ្ហា។ ក្បាលដីសរុបចំនួន៦៣១ក្បាល ស្មើនឹង៦៨៥,៧៥ហិកតា ក្នុងនោះដីកសិកម្មចំនួន៤០៥ក្បាលដី ស្មើនឹង៦៥២,៨៦ហិកតា និងដីលំនៅដ្ឋានចំនួន២២៦ក្បាលដី ស្មើនឹង៣២,៨៩ហិកតា ក្នុងនោះដីដែលបានកាប់រានក្រោយបទបញ្ជាលេខ០១ ចំនួន១២៦ក្បាលដី ស្មើនឹង១០២,៧១ហិកតា

- មានភ្ញៀវទេសចរចំនួន១.៩៤៣នាក់មកទស្សនាតំបន់អភិរក្សជីវចម្រុះវ៉ឺនសៃ-សៀមប៉ាង កំពង់ធំ-សៀមរាប តំបន់អភិរក្សសត្វក្រៀលអាងត្រពាំងថ្មនិងព្រៃការពារព្រះវិហារដោយសហគមន៍មូលដ្ឋានទទួលប្រាក់ចំណូលចំនួន១០.៧៦០ដុល្លារ

- កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ចំនួន០៤ មានផ្ទៃដីសរុបចំនួន២.៥៦៦ហិកតា ក្នុងនោះខេត្តស្ទឹងត្រែងចំនួន២កន្លែងមានផ្ទៃដីទំហំ៧៦៤ហិកតា និងខេត្តព្រះវិហារចំនួន២កន្លែង មានផ្ទៃដីទំហំ១.៨០២ហិកតា

- ចុះសាកល្បងធ្វើសុរុក្ខកម្មព្រៃឈើតាមបែបប្រពៃណីនៅព្រៃសហគមន៍អូរបាក់ត្រា ឃុំព្រងិល ស្រុកក្រវាញ ខេត្តពោធិ៍សាត់ លើផ្ទៃដីទំហំ០៤ហិកតា ដែលមានអ្នកចូលរួមចំនួន១៧នាក់ ស្ត្រីចំនួន០២នាក់។

**៤.៣ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ**

- ក្នុងត្រីមាសទី១ ឆ្នាំ២០១៥នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាៈ សត្វចំណូលថ្មីចំនួន១៤០ក្បាល សត្វកើតថ្មីចំនួន១៥ក្បាល សត្វដោះលែងចំនួន១១៨ក្បាល សត្វស្លាប់ចំនួន១៧ក្បាល ព្យាបាលសត្វចំនួន៦៦ក្បាល យកសំណាកទៅពិសោធន៍ចំនួន១៨ក្បាល ធ្វើឲ្យសន្លប់ចំនួន៣១ក្បាល ទម្លាក់សត្វល្អិតចំនួន៥១ក្បាល វះកាត់សាកសពសត្វចំនួន១១ក្បាល ដាក់លេខកូដចំនួន៤ក្បាល ចាក់វ៉ាក់សាំងចំនួន៤០ក្បាល សាងសង់ទ្រុងសត្វថ្មីលើផ្ទៃដីចំនួន៣៧,២០ម២ ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន៤១០ម២ សង់បង្គោលភ្លើងចំនួន៥ដើម តបណ្ដាញភ្លើងចំនួន៣០០ម៉ែត្រ ឆ្ការអនាម័យព្រៃចំនួន៥៥.៧១០ម២ ដាំកូនឈើចំនួន៨០១ដើម បណ្ដុះផ្កាលម្អចំនួន៧៧ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន១.៦០០នាក់

- ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្ដាមមេ-បាពូជ និងកូនស្វាក្ដាមចំនួន៤២.៤៩៧ក្បាល និងបាននាំចេញចំនួន៩៥ក្បាល។

**៤.៤ គម្រោងអភិរក្សសត្វក្រពើភ្នំកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ**

- ត្រួតពិនិត្យដែនជម្រកក្រពើនៅស្ទឹងអារ៉ែង ស្ទឹងដាច់ ស្រុកថ្មបាំង ខេត្តកោះកុង និងតាមដានការបំលាស់ទីក្រពើដោះលែងកាលពីឆ្នាំ២០១២ និង២០១៤ ដោយវិទ្យុសំឡេង(Radio Tracking) រកឃើញក្រពើចំនួន០២ក្បាល

- ក្រុមល្បាតសហគមន៍ចំនួន២២នាក់បន្តល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន០៤គឺនៅអារ៉ែង ឆាយរាប តំបន់ស្ពានក្រពើក្នុងឃុំតាតៃលើ ខេត្តកោះកុង និងអូរសោម ខេត្តពោធិ៍សាត់

- បន្តរៀបចំចម្ការពូជផ្ទង់ជាផ្នែកមួយនៃការអភិរក្សសេនេទិចក្រៅតំបន់ទំហំ៥ហិកតាសម្រាប់ឆ្នាំ២០១៥នេះ

- បន្តការចុះស្រាវជ្រាវអំពីសត្វល្អិត Leptocybe invasa នៅក្នុងស្ថានីយដាំឈើចំនួន៣ទីតាំង (មានក ស្ទួលទ្រេត ក្រសាំង) និងក្រុមហ៊ុន Kamarkara។ ជាលទ្ធផលនៃការស្រាវជ្រាវបានរកឃើញនិងប្រមូលសំណាកនៃសត្វល្អិតនៅក្នុងចម្ការឈើប្រេងខ្យល់ (Eucalyptus K7) ខេត្តបន្ទាយមានជ័យ ហើយក្រុមការងារនឹងបន្តចុះស្រាវជ្រាវលើកទី២ នៅតំបន់ផ្សេងៗទៀត។

**៤.៥ ការងារដាំដើមឈើ**

- ក្នុងត្រីមាសទី១ ឆ្នាំ២០១៥នេះ ការងារដាំឈើទូទាំងប្រទេសសម្រេចឈូសឆាយដីព្រៃបានទំហំចំនួន១.៤៥០ហិកតា និងបណ្ដុះកូនឈើចំនួន១២២.៥០០ដើម

- ការដាំឈើជាចម្ការថ្មីរបស់រដ្ឋបាលព្រៃឈើនៅតាមបណ្ដាស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើចំនួន៣ទីតាំង ដោយបណ្ដុះកូនឈើបានចំនួន៥៥០.០០០ដើម ឈូសឆាយដីព្រៃបានចំនួន១៥០ហិកតា ការពារនិងថែទាំចម្ការចាស់ក្នុងស្ថានីយដាំឈើចំនួន១០ មានផ្ទៃដីចំនួន២.៨១៨ហិកតា

- ក្រុមហ៊ុន ស៊ីងបាយអូថេក(ខេមបូឌា) ខូអិលធីឌី ជាដៃគូបានធ្វើការកាប់ឆ្ការនិងឈូសឆាយសម្អាតដីទំហំ១៥០ហិកតា និងផលិតពូជកូនឈើបានចំនួន៦០០.០០០ដើម

- ក្រុមហ៊ុន អូជី (ខេមបូឌា) ផ្លេនថេសិន ហ្វរិស ខមភេនី លីមីធីត បានរៀបចំដាំពិសោធន៍ពូជលើទំហំដី ៥ហិកតា

- ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចឈូសឆាយបានចំនួន១.១៥០ហិកតា

- ថ្នាលបណ្ដុះកូនឈើរបស់រដ្ឋបាលព្រៃឈើ ថ្នាលបណ្ដុះកូនឈើសម្ដេចតេជោ និងថ្នាលបណ្ដុះកូនឈើជាលក្ខណៈគ្រួសារ បានស្ទូងគ្រាប់ចូលថង់ចំនួន៧៥២.៥០០ថង់ និងរៀបចំសួនអាពាហ៍ពិពាហ៍ចំនួន៣៣កន្លែង នៅក្នុងខណ្ឌរដ្ឋបាលព្រៃឈើចំនួន១៨ លើផ្ទៃដីទំហំ៤១៣ហិកតា

- កំពុងថែទាំឡូត៍ស្រាវជ្រាវកសិ-រុក្ខកម្មទំហំ០៥ហិកតា ដែលមានទីតាំងនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្ដារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ

-ក្រុមការងារបានសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីកំណត់អំពីទីតាំងសម្រាប់ប្រារព្ធពិធីបុណ្យរុក្ខទិវា នាពេលខាងមុខ។

### ៤.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញឈើកែច្នៃជូនក្រុមហ៊ុនចំនួន៤ ដែលមានបរិមាណឈើកែច្នៃគ្រប់ប្រភេទចំនួន ៦.៣៣៦ម៣ និងដើមចន្ទន៍ក្រស្នា(រុក្ខជាតិរស់)ជូនក្រុមហ៊ុនចំនួន១ ស្មើនឹង៧២ដើម

- ពិនិត្យ និងរៀបចំកំណត់កូតាអនុញ្ញាតឲ្យបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើ រោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើប្រភេទតូច និងឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើជាវត្ថុធាតុដើមមានលក្ខណៈឧស្សាហកម្មនិងសិប្បកម្ម សម្រាប់ឆ្នាំ២០១៥ របស់ខណ្ឌរដ្ឋបាលព្រៃឈើទាំង២១ សម្រេចបាន៖ បង្កើតរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើធុនតូចចំនួន៧៣៣កន្លែង បង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើចំនួន៥១៩កន្លែង និងឡគ្រប់ប្រភេទដែលប្រើប្រាស់ផល អនុផលព្រៃឈើចំនួន១៩កន្លែង។

### ៤.៧ ការងារចំណូលព្រៃឈើ

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជន៖ ឈើហ៊ុបមូលសរុបចំនួន ២៨.៤៦៦ម៣ កូនឈើចំនួន២៦៤.៥២៣ដើម អុសចម្រុះចំនួន៣៣.៥១៦ស្ទែរ និងជ័រទឹកចំនួន៣៥១តោន

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចេញជូនក្រុមហ៊ុនចំនួន៣ ស្មើនឹង២៣សន្លឹក ដែលមានបរិមាណឈើកែច្នៃចំនួន២.៧២០ម៣

- ផ្តល់លិខិតសម្រាប់បំពេញលើករណីបង្កើតរោងសិប្បកម្មកែច្នៃផល អនុផលព្រៃឈើចំនួន៣១៦សន្លឹក និងបង្កើតរោងសន្និធិលក់ចែកចាយផល អនុផលព្រៃឈើចំនួន៤៣៥សន្លឹកជូនខណ្ឌរដ្ឋបាលព្រៃឈើចំនួន១៣

- ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន៤.៣២៣.៦៩២.០៤៨រៀល និងចំណូលពីសេវាសាធារណៈចំនួន១.៧២១.១៤៣.៦៥៤រៀល និង៧៨.៧០៤,៨៦ដុល្លារ។

### ៤.៨ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៥នេះ សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន៥១០ករណី ដោយបញ្ជូនទៅតុលាការចំនួន៣៨៥ករណី និងពិន័យអន្តរការណ៍ចំនួន១២៥ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន១៩៣ម៣ ឈើអារចំនួន១.៤៩៥ម៣ ឈើក្រាក់គ្រញូងចំនួន៣៦ម៣និង១.១៥៤គ.ក្រ សត្វព្រៃចម្រុះប្រភេទចំនួន៧៦២គ.ក្រនិង៦៧៥ក្បាល និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន៤០៨ហិកតាត្រូវបានបញ្ជូនសំណុំរឿងទៅតុលាការចំនួន៤០ករណី និងបានដកហូតរណារយន្តបានចំនួន១០គ្រឿង

- បាននឹងដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃដែលបានទទួលទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ(Case Tracking System-CTS) ដើម្បីរៀបចំឲ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ធ្វើការឆ្លើយតបរបស់សលើព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលមានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន ៣៩៩ករណី។ ការចុះផ្សាយនេះបានឆ្លុះបញ្ចាំងពីចំណុចវិជ្ជមាន និងអវិជ្ជមានផងដែរ ហើយអត្ថបទសារព័ត៌មានដែលចុះផ្សាយចំនួន១១០ករណី និងបានធ្វើការជ្រើសរើសរួចបញ្ជូនទៅបណ្តាខណ្ឌរដ្ឋបាលព្រៃឈើដើម្បីបំភ្លឺបានចំនួន២១ករណី។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៤-២០១៥ សរុបបានចំនួន១២.២៨៥តោន ស្មើ១០២,៣៨% នៃផែនការ ១២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៦.៧១៥តោន

- នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៥ សរុបបានចំនួន៨៥.២៥០តោន ស្មើ២៤,៣៦% នៃផែនការ ៣៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៣៤.៧៥០តោន

- នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៥ សរុបបានចំនួន២៣.១៥៥តោន ស្មើ១៥,៤៤% នៃផែនការ ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១១.៨៤៥តោន(មូលហេតុនៃការថយចុះគឺបណ្តាលមកពីការប្រែប្រួលអាកាសធាតុ)។

៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៥

- សរុបចំនួន២២.២៣៥តោន ស្មើ២០,២១% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាថយចុះចំនួន៤.២៦៥តោន។

**៥.២ វារីវប្បកម្ម**

- ការចិញ្ចឹមត្រីនិងបង្គា សរុបបានចំនួន២៥.៥៣០តោន ស្មើ១៧,៧៣% នៃផែនការ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៣.៥៣០តោន

- ការចិញ្ចឹមក្រពើ សរុបបានចំនួន២៥.០០០ក្បាល ស្មើ១០% នៃផែនការ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន១០.០០០ក្បាល

- ការភ្ញាស់កូនត្រីពូជ សរុបបានចំនួនប្រមាណ២៧.០០០.០០០កូន ស្មើ១៥% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួនប្រមាណ៤.០០០.០០០កូន។

**៥.៣ ការកែច្នៃផលនេសាទ**

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៤-២០១៥ សរុបបានចំនួន១៧.៥០០តោន ស្មើ២១,៣៤%នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២.៥០០តោន

- ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៥ សរុបបានចំនួន២.៣០០តោន ស្មើ២៨,៧៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២០០តោន

- ការផលិតទឹកត្រី សរុបបានចំនួន១៤.០០០.០០០លីត្រ ស្មើ២៨% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៤.០០០.០០០លីត្រ។

**៥.៤ ការនាំចេញផលនេសាទ**

- ផលនេសាទស្រស់ សរុបបានចំនួន២.៨៥០តោន ស្មើ១៩% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន២៥០តោន

- ផលនេសាទកែច្នៃ សរុបបានចំនួន១.៦៥០តោន ស្មើ៣៣% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៥០តោន។

**៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស**

- សម្រាប់ខែមករា ឆ្នាំ២០១៥នេះសំណុំរឿងបទល្មើសជលផលសរុបចំនួន១៧៩ករណីនៅតំបន់ទឹកសាប។

**៥.៦ ការប្រមូលថវិកា**

- ចំណូលពីវិស័យជលផល សរុបបានចំនួន៩៤៧.២៦៨.៥០០រៀល ស្មើ៣១,៥៨% នៃផែនការ៣.០០០.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នា ថយចុះចំនួន៤៤៨.៨៥១.៧៥០រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ធ្វើពិសោធន៍(ពូជ ជី ថ្នាំកសិកម្ម...)ចំនួន៦១ប្រភេទ នៅ៣៥២កន្លែង និងអង្កេតបានចំនួន៦ប្រភេទ ដោយធ្វើសម្ភាសន៍កសិករចំនួន១៥០នាក់ និងបែងចែកឯកសារបោះពុម្ពសរុបចំនួន២.៥៨០ច្បាប់

- បន្តអភិរក្សពូជដំណាំចំនួន៣១ប្រភេទ សរុបចំនួន៧.៦៥៤បញ្ជីក/សំណាក ក្នុងនោះមានស្រូវចំនួន៦.៦៥២បញ្ជីក/សំណាក ស្រង៉ែចំនួន២៩១បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន២៩ប្រភេទ ស្មើ៧១១បញ្ជីក/សំណាក

- ធ្វើទិវាស្រែបង្ហាញ និងវាយតម្លៃចំនួន០៦កន្លែងនៅខេត្តតាកែវ ស្វាយរៀង និងកំពត ដែលមានកសិករចូលរួមសរុបចំនួន៥៣៦នាក់

- ដឹកនាំនិស្សិតស្រាវជ្រាវ និងសារសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រចំនួន០៩នាក់មកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម

- បើកវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតចំនួន០២លើក ដែលមានអ្នកចូលរួមសរុបចំនួន១០២នាក់

- ចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងសន្និបាតក្នុងប្រទេសចំនួន០៨លើក ដែលមានមន្ត្រីចូលរួមសរុបចំនួន១០នាក់ និងក្រៅប្រទេសចំនួន០៨លើក ដែលមានថ្នាក់ដឹកនាំនិងមន្ត្រីសរុបចំនួន០៩នាក់

- ចូលរួមប្រជុំ និងសិក្ខាសាលាផ្សេងៗនៅក្នុងប្រទេសសរុបចំនួន៤១លើក និងក្រៅប្រទេសសរុបចំនួន០៣លើក នៅប្រទេសអ៊ីតាលី និងប្រទេសឡាវ

- ការស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មក្នុងគេហទំព័រ www.cardi.org.kh និង www.crkb.org.kh មានអ្នកចូលរួមសរុបចំនួន៨៩.៣១៣នាក់ គិតជាមធ្យមប្រមាណ៩៩២នាក់ក្នុងមួយថ្ងៃ។

### ៧ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានាសរុបចំនួន១.៣៥៥ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទសរុបចំនួន៩៩១ច្បាប់ និងទទួលពីរាជធានី ខេត្ត សរុបចំនួន៣១៨ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត សរុបចំនួន១.៩០៥ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ សរុបចំនួន១៧៩ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ សរុបចំនួន៨៥ច្បាប់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

### ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៧៨៦នាក់ នារីចំនួន១.៣៥៨នាក់ ស្មើនឹង២០% រួមមាន៖

+ អង្គភាពថ្នាក់កណ្តាលចំនួន៤.១២៩នាក់ ក្នុងនោះនារីចំនួន៧៨២នាក់ ស្មើនឹង១៨,៩៣%

+ អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦៥៧នាក់ ក្នុងនោះនារីចំនួន៥៧៦នាក់ ស្មើនឹង២១,៦៧%

- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន៣៨នាក់ ក្នុងនោះបោះបង់ការងារចំនួន១៦នាក់ សុំលាឈប់ពីការងារចំនួន១៨នាក់ និងមរណភាពចំនួន០៤នាក់

- ចេញច្បាប់សម្រាកប្រចាំឆ្នាំចំនួន១៦នាក់ ច្បាប់ព្យាបាលជំងឺចំនួន០៤នាក់ និងច្បាប់សម្រាកមាតុភាពចំនួន០៩នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន១៧នាក់ ផ្ទេរចូលក្រសួងចំនួន១៧នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន០៦នាក់

- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន១១០នាក់

- ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន៣២នាក់ និងក្នុងប្រទេសចំនួន៣៣នាក់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

### ៩ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- មន្ត្រីចំនួន៥រូប បានចូលរួមបើកវគ្គបណ្តុះបណ្តាលកសិករលើប្រធានបទ ស្តីពីនិរន្តរភាពនៃផលិតកម្មដំឡូងមីសម្រាប់កសិករខ្នាតតូច នៅខេត្តកំពង់ចាម ប៉ៃលិន និងខេត្តបាត់ដំបង

- បញ្ជូនមន្ត្រីចំនួន២៣រូប ចូលរួមនិងសហការរៀបចំសិក្ខាសាលា ស្តីពីកម្រិតកាកសំណល់ជាតិពុល និងកិច្ចប្រជុំលើកទី១៩ នៃក្រុមការងារជំនាញស្តីពីការធ្វើសុខដុមនីយកម្មកម្រិតកាកសំណល់ជាតិពុល នៃថ្នាំពុលកសិកម្ម នៅខេត្តសៀមរាប

- បញ្ជូនមន្ត្រីចំនួន១៨០រូប ចូលរួមសិក្ខាសាលាស្តីពីវិស័យកសិកម្មកម្ពុជា៖ ការត្រៀមជាស្រេចសម្រាប់សហគមន៍សេដ្ឋកិច្ចអាស៊ាន និងតទៅអនាគត នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ

- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាក្រៅប្រទេសសរុបចំនួន៧៤នាក់ នៅក្នុងប្រទេសចំនួន១៧

- រៀបចំលិខិតអន្តរាគមន៍ទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីស្នើសុំលិខិតឆ្លងដែនចំនួន១១ច្បាប់ ពន្យារទិដ្ឋាការស្នាក់នៅជូនក្រុមអ្នកបច្ចេកទេសចិនចំនួន១៨រូប

- រៀបចំលិខិតទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោងអាទិភាព៥ឆ្នាំ វិកិលឆ្នាំ២០១៥-២០១៩ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការហិរញ្ញប្បទានពីសាធារណរដ្ឋប្រជាមានិតចិន។

## ១០ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបចំនួន១.២២៣នាក់(ស្រី៣៩២នាក់) ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។ បន្តរៀបចំកម្មវិធីសិក្សាថ្មី២០១៥ ព្រមទាំងសិក្សាអំពីលទ្ធភាពកាត់បន្ថយចំនួនម៉ោងនិងក្រេឌីតក្នុងក្របខ័ណ្ឌកំណែទម្រង់កម្មវិធីសិក្សាឲ្យបានល្អប្រសើរ និងកំពុងសម្រួលកម្មវិធីសិក្សាលើគ្រប់ជំនាញឲ្យស្របតាមអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤។ ដឹកនាំនិស្សិតគ្រប់ជំនាញអនុវត្តការដាំបន្លែគ្រប់ប្រភេទ ចិញ្ចឹមត្រី ចិញ្ចឹមសត្វ និងកែច្នៃផលិតផលកសិកម្ម រៀបចំកែលម្អការងារពិសោធន៍ដំណាំផ្សេងៗនៅក្នុងបរិវេណសាលាជាតិ និងការគ្រោងរៀបចំចែកសញ្ញាបត្រដល់និស្សិតនាពេលខាងមុខ។ សហការជាមួយក្រសួងអប់រំយុវជននិងកីឡាក្នុងការកែលម្អកម្មវិធីសិក្សាក្នុងគោលបំណងប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀបទៅជាសាកលវិទ្យាល័យជាតិព្រែកលៀប។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបមានចំនួន១.៣៩៥នាក់(ស្រី៥២២នាក់) រួមមានៈ

- និស្សិតអាហារូបករណ៍សរុប១.១៦៩នាក់ (ស្រី៤៥៤នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩៤៣នាក់ (ស្រី៣៣២នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម២២៦នាក់(ស្រី១២៥នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃ២២៦នាក់ (ស្រី៦៨នាក់) ថ្នាក់បរិញ្ញាចំនួន២១៣នាក់(ស្រី៦៥នាក់) និងថ្នាក់បរិញ្ញារងចំនួន១៣នាក់ (ស្រី៣នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។ ដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត ជាក់ស្តែងសាលាជាតិបានខិតខំជំរុញនិស្សិតឱ្យចុះធ្វើកម្មសិក្សានៅទីវាល ដោយប្រៀបធៀបការអនុវត្តបច្ចេកទេសរបស់និស្សិតទៅនឹងចំណេះដឹងផ្នែកទ្រឹស្តី និងការចុះកម្មសិក្សានៅតាមកសិដ្ឋានដំណាំឧស្សាហកម្មផ្សេងៗ ពិសេសដំណាំកៅស៊ូ។

### ១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

និស្សិតកំពុងសិក្សាមានចំនួនសរុប៥.៩៧៧នាក់(ស្រី១.៤០០នាក់) ចែកចេញជា១០មហាវិទ្យាល័យ គឺមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមបានបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យបានរៀបចំធ្វើសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធស្តីពីការអភិវឌ្ឍកម្មវិធីសិក្សារបស់មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ និងកសិ-ឧស្សាហកម្ម ក្រោមជំនួយរបស់គម្រោងSPS និងបានធ្វើសិក្ខាសាលាជូននិស្សិតស្តីពីឱកាសទទួលអាហារូបករណ៍ពីសាកលវិទ្យាល័យ Purdue University សហរដ្ឋអាមេរិក និងឱកាសទទួលអាហារូបករណ៍ពីគម្រោង Lotus+ ទៅសិក្សានៅសាកលវិទ្យាល័យនៃសហភាពអឺរ៉ុប។ បញ្ជូនសាស្ត្រាចារ្យចូលរួមប្រជុំការងារសហប្រតិបត្តិការបច្ចេកទេសចំនួន០៤រូប នៅប្រទេសថៃ ឥណ្ឌូនេស៊ី និងនៅប្រទេសជប៉ុន។ ក្នុងកម្មវិធីផ្លាស់ប្តូរនិស្សិត សាកលវិទ្យាល័យបានទទួលនិស្សិតចំនួន៣៥នាក់ ពីសាកលវិទ្យាល័យ Duksoung Women University ប្រទេសកូរ៉េ និងបានបញ្ជូននិស្សិត២នាក់ ទៅចូលរួមកម្មវិធីបោះជំរុំនៅប្រទេសថៃលើប្រធានបទ“សេដ្ឋកិច្ចអាស៊ាន”ផងដែរ ។

គ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឲ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឲ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិ-ពាណិជ្ជកម្ម រួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឲ្យកាន់តែទូលំទូលាយ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួម ការងារដាំដុះដំណាំស្រូវប្រាំងសម្រេចបានលើផែនការ ហើយបានបញ្ចប់ជាស្ថាពរ។ រីឯទិន្នផលគឺកើន

លើសឆ្នាំមុនចំនួន៨៥គ.ក្រក្នុងមួយហិកតា។ បច្ចុប្បន្ននេះ ប្រជាកសិករបាននិងកំពុងធ្វើការច្រូតកាត់យ៉ាងមមាញឹកឲ្យទាន់ពេលវេលាដើម្បីជៀសវាងការបាត់បង់ផលស្រូវក្នុងពេលនិងក្រោយច្រូតកាត់។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅតែបន្តចាត់វិធានការជំរុញការអប់រំណែនាំដល់ប្រជាកសិករឲ្យធ្វើកសិកម្មចម្រុះបន្ថែមទៀតនៅតំបន់ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ដោយមិនត្រូវទុកដីឲ្យនៅទំនេរនោះឡើយ។ ទន្ទឹមនឹងនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានរៀបចំសន្និបាតកសិករលើកទី៦ ដើម្បីធ្វើការប្រឡងប្រជែងជ្រើសរើសកសិករឆ្នើមទូទាំងប្រទេសបានចំនួន០៧រូប ទៅតាមប្រធានបទនីមួយៗ និងការរៀបចំសន្និបាតកសិករទូទាំងប្រទេសនៅថ្ងៃទី០៧-០៨ ខែមេសា ឆ្នាំ២០១៥នេះ។

ដោយឡែក ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងផលផល កំពុងស្ថិតនៅតែជាប្រធានបទអាទិភាព ហើយដែលអង្គភាពជំនាញជាសេនាធិការនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសព្រៃឈើ ផលផល និងបទល្មើសផ្សេងៗទៀតតាមគ្រប់រូបភាពក្រោមកិច្ចសហការជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ និងតាមស្មារតីនៃអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈបណ្ឌិតការឯកភាពរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ លើសពីនេះទៅទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាលតាមផ្នែកជំនាញនីមួយៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនតាមដានការដែលបានគ្រោងទុកសម្រាប់អនុវត្តក្នុងឆ្នាំ២០១៥នេះ ក្នុងស្មារតីទទួលខុសត្រូវដោយសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

## IV- **ទិសដៅអនុវត្តបន្ត**

### **១.ផ្នែកដាំដុះ :**

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្ងៀង (អង្គរ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឲ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផលឲ្យអស់លទ្ធភាពនៅកន្លែងដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូតពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសទៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តស្រាវជ្រាវការដាំដុះសាកល្បងក្លូនកៅស៊ូប្រភេទ "Invitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះក្នុងក្របខណ្ឌនៃគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា។

### **២.ផ្នែកផលិតកម្មនិងបសុពេទ្យាបាល :**

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានីខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និង

វិធានការអន្តរាគមន៍តាមជាក់ស្តែង។ ទន្ទឹមនឹងនោះ ត្រូវធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឲ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឲ្យបានទូលំទូលាយ

- ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី H5N1 និងជំងឺផ្តាសាយ H7N9

- ពង្រឹងត្រួតពិនិត្យចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារអន្តរជាតិ ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឲ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣.ផ្នែកព្រៃឈើ :**

- ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឲ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយ

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

**៤.ផ្នែកជលផល :**

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ជំរុញពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៥ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥.ផ្នែកពាក់ព័ន្ធផ្សេងៗ :**

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្ដីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្ដាខេត្ត រាជធានី។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្ដាអង្គភាពក្រោមឱវាទនិងបណ្ដាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឲ្យមានប្រសិទ្ធភាព

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងការប្រមូលចំណូលបង់ចូលថវិកាជាតិឲ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ និងការធ្វើជាម្ចាស់ផ្ទះក្នុងការរៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសក្នុងក្របខណ្ឌអាស៊ានលើប្រធានបទ "ការអនុវត្តកសិកម្មល្អ" (Good Agricultural Practice – GAP)

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្ដាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្ដែង

- ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា និងយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យនិងចាត់វិធានការសមស្របដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីរាជការឲ្យបានហ្មត់ចត់

- ត្រៀមលក្ខណៈដើម្បីសហការរៀបចំព្រះរាជពិធីច្រត់ព្រះនង្គ័ល មច្ឆទិវា និងរុក្ខទិវា

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អនុបទក្រោមច្បាប់ ផែនការយុទ្ធសាស្ត្រ ស្តង់ដារ និងគោលការណ៍ព្រមទាំងពង្រឹងសមត្ថភាពធនធានមនុស្ស សមត្ថភាពពាក់ព័ន្ធនិងហេដ្ឋារចនាសម្ព័ន្ធទៅតាមអង្គភាពរបស់ខ្លួន ដើម្បីលើកកម្ពស់វិស័យកសិកម្មនៅកម្ពុជាក្នុងការត្រៀមលក្ខណៈសម្រាប់ការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ២០១៥ និងនាពេលអនាគត។ ទន្ទឹមនឹងនេះ ក៏ត្រូវគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត វ៉េង សាខុន